ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថាគន្លឹះ
## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពី ដុល្លារូបនីយកម្ម និងប្រព័ន្ធធនាគារនៅកម្ពុជា
Dollarization and Banking System in Cambodia

**ថ្ងៃសុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨**
**វិមានរដ្ឋសភា ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤**

**ជាបឋម នាងខ្ញុំសូមគោរព៖**

- **ឯកឧត្តម វង សូត អនុប្រធានទី២ នៃរដ្ឋសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា**
- **ឯកឧត្តម ឈាន វុន ប្រធានគណៈកម្មការទី២ នៃរដ្ឋសភា**
- **ឯកឧត្តម លោកជំទាវ ប្រធាននិងអនុប្រធានគណៈកម្មាការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និង**
- **ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា នៃរដ្ឋសភា ជាទីគោរព!**

ថ្ងៃនេះ នាងខ្ញុំមានសេចក្តីសោមនស្សរីករាយនិងកិត្តិយសជាអនេក ដែលបានដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា មកចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី ដុល្លារូបនីយកម្ម និងប្រព័ន្ធធនាគារនៅកម្ពុជា នៅវិមានរដ្ឋសភា។ នាងខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម វង សូត អនុប្រធានទី២ នៃរដ្ឋសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងសិក្ខាសាលានេះ និងបានអនុញ្ញាតឱ្យនាងខ្ញុំនិងសហការី មានឱកាសធ្វើបទបង្ហាញជូនពាក់ព័ន្ធនឹងស្ថានភាពវិស័យធនាគារ និងមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា។


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នាងខ្ញុំសូមអនុញ្ញាតគោរពជម្រាបជូនពីសមាសភាពគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ដែលមានវត្តមាននៅទីនេះ៖

- ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង
- ឯកឧត្តម យឹម លាត ទេសាភិបាលរង
- ឯកឧត្តម គីមទី កោមលី អគ្គនាយកប្រតិបត្តិការ
- ឯកឧត្តម គិត សុវណ្ណារិទ្ធ អគ្គនាយកត្រួតពិនិត្យ
- លោកបណ្ឌិត ឃូ វុណ្ណី អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ
- លោក អែម កំណាន់ អគ្គនាយករងត្រួតពិនិត្យ។

ប្រតិភូធនាគារជាតិនៃកម្ពុជា នឹងធ្វើបទបង្ហាញជូនលើប្រធានបទសំខាន់ៗ ចំនួន ៣ ដែលជាការងារស្នូលរបស់ធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

- ប្រធានបទទី១៖ តួនាទីរបស់ធនាគារកណ្តាលលើដុល្លារូបនីយកម្មនៅកម្ពុជា និងគោលនយោបាយលើកកម្ពស់ប្រាក់រៀល
- ប្រធានបទទី២៖ ស្ថានភាពប្រព័ន្ធធនាគារ និងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា និង
- ប្រធានបទទី៣៖ ការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំសូមគោរពជម្រាបជូនថា ដុល្លារូបនីយកម្មមានវត្តមាននៅកម្ពុជាតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ហើយជាង៣០ឆ្នាំកន្លងមកនេះ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមានដល់សេដ្ឋកិច្ច។ ចំពោះគុណសម្បត្តិសំខាន់គឺ ដុល្លារូបនីយកម្មបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ដោយបានសម្រួលពាណិជ្ជកម្ម ការវិនិយោគ និងគាំទ្រដល់គម្រោងអភិវឌ្ឍន៍នានា ព្រមទាំងបានបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងអន្តរជាតិ តាមរយៈការផ្តល់ទំនុកចិត្តដល់វិនិយោគិន នៅក្នុងស្ថានភាពដែលសេដ្ឋកិច្ចនិងស្ថិរភាពនយោបាយកំពុងត្រូវបានស្តារឡើងវិញ ហើយប្រាក់រៀលមិនទាន់មានស្ថិរភាពល្អ។ ទោះយ៉ាងណា នៅពេលប្រទេសជាតិកាន់តែរីកចម្រើន សេដ្ឋកិច្ចកម្ពុជាកាន់តែមានភាពប្រទាក់ក្រឡាទាំងក្នុងស្រុកនិងក្រៅប្រទេស ហើយទំហំសេដ្ឋកិច្ចក៏បានកើនឡើងផងដែរ ដែលធ្វើឱ្យកម្រិតខ្ពស់នៃដុល្លារូបនីយកម្មក្លាយជាកត្តានាំឱ្យសេដ្ឋកិច្ចងាយរងគ្រោះ ដោយសារតែធនាគារជាតិនៃកម្ពុជាមិនអាចអនុវត្តនយោបាយរូបិយវត្ថុឱ្យបានពេញលេញនិងឯករាជ្យ ដូចបណ្តាប្រទេសជឿនលឿន ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច ឬកាត់បន្ថយផលប៉ះពាល់ពីវិបត្តិបានដោយប្រសិទ្ធភាព។

ជាក់ស្តែង នៅពេលមានវិបត្តិឬកំណើនយឺតនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាមិនអាចកាត់បន្ថយអត្រាការប្រាក់គោល ដើម្បីបន្ថយអត្រាការប្រាក់នៅលើទីផ្សារ ក្នុងគោលដៅជំរុញការខ្ចីនិងការវិនិយោគបានទេ ដោយសារឥណទានភាគច្រើនលើសលុបជាប្រាក់ដុល្លារអាមេរិក ហើយអត្រាការប្រាក់នៅកម្ពុជាបានផ្ជក់នឹងអត្រាការប្រាក់នៃប្រាក់ដុល្លារអាមេរិកលើទីផ្សារហិរញ្ញវត្ថុអាមេរិក ក៏ដូចជាអន្តរជាតិ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏មិនអាចដើរតួនាទីជាអ្នកឱ្យខ្ចីចុងក្រោយទៅឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានដែរ ដោយសារការខ្ចីប្រមាណ ៨៨% ជាប្រាក់ដុល្លារអាមេរិក ដែលបច្ចុប្បន្នមានចំនួនប្រមាណ ៥០,៦ ប៊ីលានដុល្លារអាមេរិក ខណៈដែលធនាគារជាតិនៃកម្ពុជាមានទុនបម្រុងត្រឹម ២០ ប៊ីលានដុល្លារអាមេរិក ហើយក្នុងនោះ ប្រមាណ ៥៤% ជារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ម្យ៉ាងទៀត ដុល្លាររូបនីយកម្ម បានធ្វើឱ្យកម្ពុជាត្រូវទទួលរងផលប៉ះពាល់ពីការអនុវត្តនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។ ជាក់ស្តែង ចាប់ពីដើមឆ្នាំ២០២២ សហរដ្ឋអាមេរិកបានជួបនឹងបញ្ហាអត្រាអតិផរណាខ្ពស់ ដែលតម្រូវឱ្យធនាគារកណ្តាលអាមេរិកដំឡើងអត្រាការប្រាក់គោលជាបន្តបន្ទាប់ពីប្រមាណ ០,២៥% ហើយរក្សាអត្រាក្នុងកម្រិតខ្ពស់ ៥,៥% រហូតដល់បច្ចុប្បន្ន។ ការដំឡើងអត្រាការប្រាក់នេះបាននាំឱ្យអត្រាការប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិកើនឡើង ហើយតម្លៃប្រាក់ដុល្លារអាមេរិកក៏ឡើងថ្លៃតាមនោះដែរ។ កម្ពុជាមិនចង់ឱ្យប្រាក់ដុល្លារអាមេរិកឡើងថ្លៃនោះទេ ដោយសារផលប៉ះពាល់ទៅលើអំណាចទិញនៃប្រជាជនដែលមានចំណូលជាប្រាក់រៀល និងការកើនឡើងនៃសម្ពាធអតិផរណានាំចូល ហើយក៏មិនចង់ឱ្យអត្រាការប្រាក់កើនឡើងផងដែរ ដោយកម្ពុជាចង់ឱ្យវិស័យឯកជនបន្តខ្ចីដើម្បីស្តារសេដ្ឋកិច្ចឡើងវិញ។ លើសពីនេះ ដើម្បីរក្សាស្ថិរភាពតម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ធនាគារជាតិនៃកម្ពុជាត្រូវធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកតាមការចាំបាច់សំដៅស្រូបយកប្រាក់រៀលពីសេដ្ឋកិច្ច ដែលធ្វើឱ្យទុនបម្រុងអន្តរជាតិថយចុះ។ ជាក់ស្តែង នៅឆ្នាំ២០២៣កន្លងទៅ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ ដោយលក់ប្រាក់ដុល្លារអាមេរិកប្រមាណ ១៤០ លានដុល្លារអាមេរិក។ នៅក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ផ្អែកលើយន្តការទីផ្សារ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ នាងខ្ញុំសូមគោរពជម្រាបជូនថា នៅក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារឱ្យទទួលបានការរីកចម្រើនយ៉ាងឆាប់

រហ័ស ដោយទ្រព្យសកម្មប្រព័ន្ធធនាគារបានកើនឡើង ១៩៨ដង ពីឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០២៣ ស្របពេលដែលទំហំប្រាក់បញ្ញើបានកើនឡើង ២៧៨ដង។ ជាមួយគ្នានេះ ការទទួលបានសេវាហិរញ្ញវត្ថុក៏មានភាពកាន់តែប្រសើរឡើងជាលំដាប់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនគណនីប្រាក់បញ្ញើអតិថិជនដល់ ២១ លានគណនី និងគណនីឥណទានអតិថិជនដល់ ៣,៩ លានគណនី។ ការបើកគណនីធនាគារក៏ជាផ្នែកមួយនៃការកំណត់អត្តសញ្ញាណផ្លូវការរបស់បុគ្គលស្វ័យនិយោជន៍និងសហគ្រាសធុនតូចនិងមធ្យម ក្នុងការឈានចូលទៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីមានលទ្ធភាពខ្ពស់ជាងមុនក្នុងការទទួលបានហិរញ្ញប្បទានផ្លូវការក្នុងអត្រាការប្រាក់ទាប និងមានការការពារអតិថិជនខ្ពស់ ដែលនឹងសម្រួលដល់ការពង្រឹងផលិតភាព ពង្រីកអាជីវកម្ម និងការបើកផ្លូវឆ្ពោះទៅកាន់ទីផ្សារអន្តរជាតិ ជាដើម។

ការរីកចម្រើននៃប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុ បានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ និងកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា តាមរយៈការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យសេដ្ឋកិច្ច ទាំងវិស័យស្នូលដែលមានកន្លងមក និងវិស័យសក្តានុពលសម្រាប់ការធ្វើពិពិធកម្មសេដ្ឋកិច្ច រួមទាំងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យមផងដែរ ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ។ ទន្ទឹមនេះ ប្រព័ន្ធធនាគារក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយនៃផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ជាមួយភាពរឹងមាំនៃស្ថានភាពដើមទុននិងសន្ទនីយភាព ដែលបានស្រូបយកមួយផ្នែកនៃការប៉ះទង្គិចនៃវិបត្តិទៅលើសេដ្ឋកិច្ចជាតិ ព្រមទាំងបានរួមចំណែកទ្រទ្រង់និរន្តរភាព និងការរស់រាននៃអាជីវកម្ម និងគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច តាមរយៈការដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិអនុគ្រោះនានា ក្នុងក្របខ័ណ្ឌគោលនយោបាយគាំទ្រកំណើនរបស់រាជរដ្ឋាភិបាល។

ទោះយ៉ាងណា កន្លងមក វិស័យធនាគារ ជាពិសេសវិស័យមីក្រូហិរញ្ញវត្ថុ បានទទួលរងការចោទប្រកាន់ពីអង្គការក្រៅរដ្ឋាភិបាល និងក្រុមអគតិមួយចំនួន ដែលលើកឡើងថាបញ្ហាសង្គមមួយចំនួន គឺកើតចេញពីការខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ជាការពិត បញ្ហានេះជាករណីតិចតួចប៉ុណ្ណោះ ហើយជាពិសេសភាគច្រើនកើតឡើងដោយសារកម្ចីក្រៅផ្លូវការនិងចំណេះដឹងហិរញ្ញវត្ថុនៅមានកម្រិត ដែលធ្វើឱ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុមិនចំទិសដៅនិងមិនមានប្រសិទ្ធភាព ហើយបែរកើតជាផលវិបាកអវិជ្ជមាន។ ផ្ទុយពីការលើកឡើងនេះ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាត្រូវបានទទួលស្គាល់ថាជាកាតាលីករដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដែលស្របទៅនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវឯករាជ្យជាបន្តបន្ទាប់ ដូចជា

ក្នុងសៀវភៅរបស់ លោក រ៉ុន បេវ៉ាកក្វា ដែលបានបោះផ្សាយនៅឆ្នាំ២០១៧ និងអត្ថបទស្រាវជ្រាវរបស់លោក Frank Bliss ដែលជាសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវជនជាតិអាល្លឺម៉ង់ នៅឆ្នាំ២០២២។

លើសពីនេះ ធនាគារជាតិនៃកម្ពុជា រួមជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា បាននិងកំពុងសហការលើកកម្ពស់បរិយាបន្ននិងចំណេះដឹងហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ដើម្បីឱ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ដែលនឹងរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រ។ ស្របគ្នានេះដែរ កាលពីចុងខែកក្កដា ឆ្នាំ២០២៤កន្លងទៅថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា និងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានចេញសេចក្តីថ្លែងការណ៍រួមស្តីពី ដំណើរការពិគ្រោះយោបល់ជាមួយពហុភាគីពាក់ព័ន្ធ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលបានរៀបចំជាបន្តបន្ទាប់ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងគោលបំណងបង្កើតឱ្យមានការយល់ដឹងរួមគ្នាអំពីបញ្ហាប្រឈមនានា ការកំណត់សកម្មភាពនិងការប្តេជ្ញាចិត្តជាក់លាក់ ដើម្បីគាំទ្រការដោះស្រាយ និងចាប់យកកាលានុវត្តភាពក្នុងការពង្រឹងវិស័យធនាគារ។

ទន្ទឹមនឹងការអភិវឌ្ឍប្រព័ន្ធធនាគារ នាងខ្ញុំក៏សូមរំលេចផងដែរ ពីសារៈសំខាន់នៃប្រព័ន្ធការពារប្រាក់បញ្ញើ ដែលនៅប្រទេសភាគច្រើន បានដើរតួយ៉ាងសំខាន់ជាសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ តាមរយៈការកាត់បន្ថយហានិភ័យនៃប្រាក់បញ្ញើ ការការពារអតិថិជនជាអ្នកដាក់ប្រាក់ និងការពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បានបង្កើតឱ្យមាននូវអង្គភាពការពារប្រាក់បញ្ញើនិងក្របខ័ណ្ឌដំណោះស្រាយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយបាននិងកំពុងពង្រឹងក្របខ័ណ្ឌស្ថាប័ននិងគតិយុត្តិ ដើម្បីពង្រឹងតួនាទីអង្គភាពនេះ ក្នុងការអនុវត្តតួនាទីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពនាពេលខាងមុខ។

ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការកើនឡើងនៃអាជីវកម្មនិងពាណិជ្ជកម្មអនឡាញ ប្រព័ន្ធទូទាត់ត្រូវបានបន្តធ្វើទំនើបកម្ម ដើម្បីសម្រួលការទូទាត់ឱ្យកាន់តែមានភាពងាយស្រួល សុវត្ថិភាព និងឆាប់រហ័ស និងចំណាយប្រតិបត្តិការទាប មិនថាការទូទាត់ឆ្លងគ្រឹះស្ថានក្នុងស្រុក និងការទូទាត់ឆ្លងដែននោះទេ ដែលបានជំរុញសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។ ក្នុងចំណោមប្រព័ន្ធទូទាត់ទាំងអស់ ប្រព័ន្ធទូទាត់បាគងបាននិងកំពុងបំពេញមុខងារកាន់តែសម្បូរបែបជូនដល់អ្នកប្រើប្រាស់ ដែលបានជំរុញការប្រើប្រាស់ប្រព័ន្ធនេះឱ្យកើនឡើងជាបន្តបន្ទាប់ និងរួមចំណែកដល់ការ

លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងមុខមាត់ កម្ពុជានៅលើឆាកអន្តរជាតិ។ គិតត្រឹមឆមាស ទី១នេះ ទំហំប្រតិបត្តិការជាប្រាក់រៀលតាមប្រព័ន្ធបាគង មានចំនួន ៧៧,៤ ទ្រីលានរៀលដែល កើន ២,៥ ដង ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន និងទំហំប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៦,៣ ប៊ីលានដុល្លារអាមេរិកដែលមានកំណើន ២,១ ដង។ បន្ថែមលើនេះ ធនាគារជាតិនៃ កម្ពុជាបានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ឡាវ វៀតណាម និង ក្រុមហ៊ុនអន្តរជាតិយូញៀនផេ ព្រមទាំងកំពុងពង្រីកគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេស ផ្សេងទៀតក្នុងតំបន់និងដៃគូសហការនានា ដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា កូរ៉េ សិង្ហបុរី ម៉ាឡេស៊ី និងក្រុមហ៊ុនអាលីផេ ជាដើម។ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ ធនាគារជាតិ នៃកម្ពុជា ក៏បានសម្ពោធដាក់ឱ្យដំណើរការបឋមនូវកម្មវិធីទូតាត់បាគងទេសចរ (Bakong Tourist App) ដែលជាមធ្យោបាយទូទាត់តាមរយៈ QR Code ដោយផ្តល់ភាពងាយស្រួលដល់ការ ទូទាត់របស់ភ្ញៀវទេសចរអន្តរជាតិ ដែលអញ្ជើញមកទស្សនានៅកម្ពុជា។

- **ឯកឧត្តម អនុប្រធានទី២ នៃរដ្ឋសភា ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរដ្ឋសភា ទាំងអស់ ជាទីគោរព!**

នៅឆ្នាំ២០២៤ ក៏ដូចជានារយៈពេលមធ្យមនិងវែងខាងមុខ សេដ្ឋកិច្ចកម្ពុជារំពឹងដោយ សុទិដ្ឋិនិយមថានឹងបន្តអភិវឌ្ឍថែមទៀត ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែល អភិវឌ្ឍកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេស មានចំណូលខ្ពស់នាឆ្នាំ២០៥០។ ទោះយ៉ាងណា ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក ភាពតានតឹងភូមិសាស្ត្រនយោបាយជាពិសេសសង្គ្រាម ការថយចុះកំណើនសេដ្ឋកិច្ចចិន និង ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ហានិភ័យជាច្រើនក៏បាននិងកំពុងបង្កជាឧបសគ្គដល់ ការសម្រេចបានគោលដៅនេះផងដែរ។

ស្ថិតក្នុងស្ថានភាពនេះ និងដើម្បីបន្តអភិវឌ្ឍវិស័យធនាគារ សំដៅរួមចំណែកគាំទ្រ គោលដៅអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាសូមគោរព ស្នើសុំ សម្តេចប្រធាន ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា នៃរដ្ឋសភា បន្តគាំទ្រ ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តមុខងារ-ភារកិច្ច ដូចជា ការលើកកម្ពស់ការប្រើប្រាស់ ប្រាក់រៀលដើម្បីពង្រឹងការអនុវត្តនយោបាយរូបិយវត្ថុ ការអភិវឌ្ឍប្រព័ន្ធធនាគារ ការពង្រឹង ការការពារប្រាក់បញ្ញើ កិច្ចការពារអតិថិជន និងជាពិសេសការអនុម័តច្បាប់សំខាន់ៗពាក់ព័ន្ធ នឹងវិស័យធនាគារ ដែលជួយគាំទ្រនិងជំរុញការរីកចម្រើនរបស់ប្រព័ន្ធធនាគារ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគោរពថ្លែងអំណរគុណដល់ សម្តេចប្រធានរដ្ឋសភា ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃរដ្ឋសភា ដែលកន្លងមកបានអនុម័តច្បាប់ ដែលអំណោយផលដល់ការរីកចម្រើននៃសេដ្ឋកិច្ចនិងសង្គម ដែលក្នុងនោះមានការអភិវឌ្ឍប្រព័ន្ធធនាគារផងដែរ ក្រោមដំបូលសុខសន្តិភាព ដែលមាន **សម្តេចតេជោ** ជាអគ្គស្ថាបនិកដ៏ឆ្នើម និងការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដែលមាន **សម្តេចមហាបវរធិបតី** ជានាយករដ្ឋមន្ត្រី។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពជូនពរ សម្តេចប្រធាន ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរដ្ឋសភាទាំងអស់ សូមមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។

**សូមអរគុណ!**